01455859

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 04 / 2017
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E457/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលកំណត់សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និង សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ក្នុងសំណុំរឿង ០០២/០២

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់សហព្រះរាជអាជ្ញា ដែលបានដាក់នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៧ សុំពន្យារពេលកំណត់សម្រាប់ដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃទី ២៤ ខែ មេសា រហូតដល់ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧ និងសុំពន្យារពេលចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលពីថ្ងៃទី ០៥ មិថុនា ទៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៧ វិញ ("សំណើរបស់ ក.ស.ព") (ឯកសារ E457 កថាខណ្ឌ ៧)។ ក.ស.ព បានស្នើសុំបន្ថែមទៀតឱ្យកាត់បន្ថយពេលវេលាឱ្យបានសមាមាត្រទៅនឹងពេលវេលាដែលបានផ្តល់ទៅឱ្យភាគីនីមួយៗ សម្រាប់ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សា ដើម្បីធានាមិនឱ្យមានការពន្យារពេលការបញ្ចប់ការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២។ នៅក្នុងការឆ្លើយតបរបស់ពួកគេទៅនឹងសំណើរបស់ ក.ស.ព មេធាវីការពារក្តី ខៀវ សំផន និង សហមេធាវីនាំមុខ គាំទ្រដល់ការពន្យារពេលកំណត់សម្រាប់ដាក់សារណាបញ្ចប់កិច្ច

ពិភាក្សាដេញដោល ទោះបីជាពួកគេមានការយល់ឃើញផ្សេងពីគ្នាពាក់ព័ន្ធនឹងពេលវេលាជាក់ស្តែងសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល និងពេលវេលាដែលភាគីនីមួយៗទទួលបានក៏ដោយ។ មេធាវីការពារក្តី នួន ជា ជំទាស់ទៅនឹងសំណើរបស់ ក.ស.ព។

២. តាមរយៈអ៊ីម៉ែលនៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៧ អង្គជំនុំជម្រះបានសម្រេចទទួលយកសំណើរបស់ ក.ស.ព មួយផ្នែក ដោយពន្យារពេលកំណត់សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ទៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ និងបានជូនដំណឹងដល់ភាគីថា រាល់បញ្ហាទាំងអស់ផ្សេងទៀតដែលបានលើកឡើងនៅក្នុងសំណើសុំរបស់ពួកគេ រួមជាមួយសំអាងហេតុនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ នឹងផ្តល់ជូនក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន (ឯកសារ E457/5.1.2)។ បន្ទាប់ពីបានជូនដំណឹងតាមរយៈអ៊ីម៉ែលនេះ នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៧ សហមេធាវីនាំមុខបានដាក់សំណើមួយបន្ថែមទៀត ("សំណើទី២ របស់សហមេធាវីនាំមុខ") ដោយស្នើសុំពន្យារពេលកំណត់សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលម្តងទៀតដល់ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៧ ចំណែកឯពេលវេលាសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនឹងផ្តល់ជូនតាមក្រោយ។ មេធាវីការពារក្តី នួន ជា ជំទាស់ទៅនឹងសំណើទី២ របស់សហមេធាវីនាំមុខ (ឯកសារ E457/5)។ មិនមានការឆ្លើយតបពីភាគីផ្សេងទេ តែពួកគេបានលើកឡើងថា ពួកគេនៅតែប្រកាន់យកទឡ្ហីករណ៍របស់ខ្លួនដែលបានលើកឡើងនៅក្នុងសារណាមុនៗដដែល។

**<u>សំណើរបស់ ក.ស.ព និង ចម្លើយតប</u>**

៣. សំណើរបស់ ក.ស.ព ស្នើសុំពន្យារពេលដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ដោយសារអង្គភាពប្រតិចារឹក (TU) កំពុងធ្វើការកែតម្រូវប្រតិចារឹកជាច្រើន ដែលធ្វើឱ្យភាគីមានការលំបាកក្នុងការសំអាងទៅលើកំណត់ហេតុតុលាការនៅក្នុងសារណារបស់ខ្លួន (ឯកសារ E457 កថាខណ្ឌ ២)។ សំណើនេះលើកឡើងថា ការពន្យារពេលនេះនឹងជួយឱ្យភាគីមានឱកាសដ៏មានអត្ថន័យ ក្នុងការពិនិត្យមើលសំណៅចុងក្រោយនៃប្រតិចារឹកសវនាការទាំងអស់ដែលមេធាវីការពារក្តី ខៀវ សំផន និង អង្គជំនុំជម្រះសាលាដំបូងបានកំណត់អត្តសញ្ញាណជាអាទិភាព ហើយនឹងអនុញ្ញាតបន្ថែមទៀតឱ្យភាគីអាចសំអាងទៅលើប្រតិចារឹកចុងក្រោយដែលបានពិនិត្យ កែតម្រូវ "មួយចំនួនធំ" នៅក្នុងសារណារបស់ខ្លួន (ឯកសារ E457 កថា-

ខណ្ឌ ៥)។

៤. ក្នុងការឆ្លើយតបវិញ នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៧ មេធាវីការពារក្តី ខៀវ សំផន គាំទ្រដល់សំណើសុំពន្យារពេលរហូតដល់ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧ សំណើសុំពន្យារពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល និង សំណើសុំកាត់បន្ថយពេលវេលាដែលភាគីទទួលបានសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។ ទោះបីជាយ៉ាងនេះក្តី មេធាវីការពារក្តីស្នើសុំឱ្យមានពេលវេលាគ្រប់គ្រាន់ ក្នុងការរៀបចំធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន ក្រោយពេលទទួលបានសារណារបស់សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខ ហេតុនេះ មេធាវីការពារក្តីស្នើសុំធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៧ វិញ ដោយសុំរយៈពេល ៥ សប្តាហ៍ ចន្លោះពីពេលកំណត់ដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងពេលចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (ឯកសារ E457/1 កថាខណ្ឌ ១២-១៤)។

៥. នៅក្នុងការឆ្លើយតបរបស់ខ្លួន នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៧ សហមេធាវីនាំមុខគាំទ្រសំណើសុំពន្យារពេលដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរហូតដល់ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧ និងការពន្យារពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (ឯកសារ E457/2)។ ទាក់ទងនឹងចំណុចទីពីរ ពួកគេលើកឡើងថា ពួកគេត្រូវការរយៈពេលមួយថ្ងៃពេញ រួមមានសវនាការលើអង្គសេចក្តីចំនួន ៣ វគ្គសវនាការ និង ១ វគ្គសវនាការស្តីពីសំណង នៅក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។ ពួកគេយល់ថាជាការចាំបាច់ផងដែរ ដែលត្រូវរក្សាទុករយៈពេលមួយថ្ងៃពេញសម្រាប់ធ្វើសេចក្តីសន្និដ្ឋានតប ដោយត្រូវបែងចែករវាងសហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខ។ ចុងក្រោយ ពួកគេស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យអង្គភាពប្រតិចារឹក ជូនដំណឹងអំពីកាលបរិច្ឆេទបឋមនៃការបញ្ចប់ការត្រួតពិនិត្យ និងកែតម្រូវប្រតិចារឹកសវនាការទាំងអស់ដែលមានសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ E457/2 កថាខណ្ឌ ៣)។

៦. ក្នុងការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៧ មេធាវីការពារក្តី នួន ជា ជំទាស់ទៅនឹងសំណើរបស់ ក.ស.ព ដោយលើកឡើងថា សំណើសុំពន្យារពេលមិនមានប្រសិទ្ធិភាព និង មិនសមហេតុផលទេ (ឯកសារ E457/3 កថា-ខណ្ឌ ៦)។

មេធាវីការពារក្ដីលើកឡើងថា ប្រសិនបើទទួលយកតាមសំណើសុំពន្យារពេលដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ប្រតិចារឹកមួយចំនួនធំទៀតដែលមិនទាន់បញ្ចប់ការត្រួតពិនិត្យ និងកែតម្រូវនោះ នឹងមិនអាចបញ្ចប់បានទៅតាមកាលបរិច្ឆេទចុងក្រោយថ្មីនេះទេ (ឯកសារ E457/3 កថាខណ្ឌ ៦-៨)។ មេធាវីការពារក្ដីលើកឡើងបន្ថែមទៀតថា ប្រតិចារឹកជាង ១០០ ជាភាសាអង់គ្លេស មិនទាន់បានពិនិត្យមើលនៅឡើយ ហើយមេធាវីការពារក្ដីមិនអាចបញ្ចូលការកែតម្រូវប្រតិចារឹកដែលចាំបាច់ទាំងនេះ ទៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន ត្រឹមតែរយៈពេលបន្ថែម ១៥ ថ្ងៃបានឡើយ (ឯកសារ E457/3 កថាខណ្ឌ ៩)។ មេធាវីការពារក្ដីក៏ជំទាស់ផងដែរទៅនឹងការកាត់បន្ថយពេលវេលាដែលភាគីទទួលបាន សម្រាប់ធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដោយសារភាពស្មុគស្មាញនៃរឿងក្ដីនេះ តម្រូវឱ្យមេធាវីការពារក្ដីត្រូវការរយៈពេល ២ ថ្ងៃពេញ ក្នុងការធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួន។ ដោយសារតែសារណានឹងត្រូវដាក់តែមួយភាសា មេធាវីការពារក្ដីលើកឡើងថា ការធ្វើសេចក្ដីសន្និដ្ឋានរបស់ភាគីនីមួយៗ ព្រមទាំងការឆ្លើយតបទៅភាគីផ្សេងទៀតឱ្យបានសមស្របនោះ ត្រូវតែធ្វើឡើងនៅក្នុងអំឡុងពេលធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល (ឯកសារ E457/3 កថាខណ្ឌ ១៥)។ មេធាវីការពារក្ដីអះអាងថា សិទ្ធិរបស់ នួន ជា ក្នុងការធ្វើសេចក្ដីសន្និដ្ឋានជាសាធារណៈ ព្រមទាំងសិទ្ធិទទួលបានភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះនឹងត្រូវរំលោភបំពាន ប្រសិនបើមានការកាត់បន្ថយពេលវេលាដែល នួន ជា ទទួលបាន។ មេធាវីការពារក្ដីគូសបញ្ជាក់ថា ការពន្លឿនកិច្ចដំណើរការនីតិវិធីមិនត្រូវឱ្យប៉ះពាល់ដល់ភាពយុត្តិធម៌នោះឡើយ (ឯកសារ E457/3 កថាខណ្ឌ ១៦-១៧)។

៧. មេធាវីការពារក្ដី នួន ជា ក៏បានស្នើសុំឱ្យអង្គជំនុំជម្រះអនុញ្ញាតដល់ភាគីក្នុងការដាក់សំណើសុំកែតម្រូវលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ដែលរួមមាន ការកែតម្រូវលើចំណុចយោង និងការកែតម្រូវលើខ្លឹមសារដែលចាំបាច់ ក្រោយពេលប្រតិចារឹកទាំងអស់ត្រូវបានបញ្ចប់ការត្រួតពិនិត្យ និងកែតម្រូវ។ ទាក់ទងនឹងចំណុចនេះ មេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះណែនាំទៅការិយាល័យរដ្ឋបាល ធានាឱ្យមានថវិកាបន្ថែមចាំបាច់សម្រាប់មេធាវីការពារក្ដីក្នុងការរៀបចំសំណើសុំកែតម្រូវរបស់ខ្លួន (ឯកសារ E457/3 កថាខណ្ឌ ១០-១២)។ ចុងក្រោយ មេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះ ធ្វើការបញ្ជាក់បន្ថែមទៀតជាមួយអង្គភាពប្រតិចារឹកអំពីស្ថានភាពប្រតិចារឹក (ឯកសារ E457/3 កថាខណ្ឌ ១៩-២០, ២១(ឃ))។

**<u>សំណើទី២ របស់សហមេធាវីនាំមុខ និង ចម្លើយតប</u>**

៨. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៧ សហមេធាវីនាំមុខបានដាក់សំណើទី២របស់ខ្លួន។ ដោយផ្អែកលើមូលដ្ឋានថា ប្រតិចារឹកនៃសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នឹងត្រូវបានពិនិត្យ និងបញ្ចប់ត្រឹមថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧ នោះ សហមេធាវីនាំមុខស្នើសុំពន្យារពេលកំណត់សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរហូតដល់ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៧ ដើម្បីឱ្យពួកគេអាចបញ្ចូលការកែតម្រូវនានានៅក្នុងប្រតិចារឹក ទៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន ដោយបញ្ចៀសបាននូវភាពចាំបាច់នៃការដាក់សំណើសុំកែតម្រូវ (ឯកសារ E457/4 កថាខណ្ឌ ៨-១០)។ ពួកគេស្នើសុំពន្យារពេលបន្ថែមទៀតសម្រាប់ធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល រហូតដល់ពេលដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរួចរាល់ ដោយពុំបានស្នើសុំកាលបរិច្ឆេទជាក់លាក់នោះទេ (ឯកសារ E457/4 កថាខណ្ឌ ១១)។

៩. ក្នុងការឆ្លើយតបទៅនឹងសំណើទី២ របស់សហមេធាវីនាំមុខ នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៧ មេធាវីការពារក្ដី នួន ជា ជំទាស់ទៅនឹងការពន្យារពេលបន្ថែមទៀតក្នុងការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងបញ្ជាក់សាជាថ្មីអំពីសំណើមុនៗរបស់ខ្លួន (ឯកសារ E457/5 កថាខណ្ឌ ៩-១៦)។ មេធាវីការពារក្ដីទទួលស្គាល់ថា ដំណោះស្រាយដែលមានប្រសិទ្ធភាពជាងនេះ គឺការពន្យារពេលកំណត់សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល រហូតទាល់តែប្រតិចារឹកទាំងអស់ត្រូវបានបញ្ចប់ មិនមែនត្រឹមតែសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះទេ (ឯកសារ E457/5 កថាខណ្ឌ ១១-១២)។ ទោះបីជាយ៉ាងនេះក្ដី ដោយសារអង្គជំនុំជម្រះបានបដិសេធសំណើនោះរួចហើយ មេធាវីការពារក្ដី នួន ជា ស្នើសុំឱ្យអង្គជំនុំជម្រះ រក្សាទុកពេលវេលាកំណត់សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ ដដែល និងសុំអនុញ្ញាតដាក់សំណើសុំកែតម្រូវរហូតដល់ចុងខែ កញ្ញា ឆ្នាំ ២០១៧ (ឯកសារ E457/5 កថាខណ្ឌ ១៣-១៦)។

**<u>ការពិភាក្សា</u>**

១០. អង្គជំនុំជម្រះសូមរំលឹកឡើងវិញថា កាលពីថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ អង្គជំនុំជម្រះរកឃើញ

ថា ទំហំ និងវិសាលភាពនៃសំណុំរឿង ០០២/០២ គឺជាហេតុផលសមស្របដែលអនុញ្ញាតឱ្យបង្កើនចំនួនទំព័រ និងពេលវេលាសម្រាប់ការរៀបចំដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលប្រសិនបើប្រៀបធៀបទៅនឹងសំណុំរឿង ០០២/០១។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ព្រមផ្តល់ជូនរហូតដល់ចំនួន ៨០០ ទំព័រសម្រាប់សហព្រះរាជអាជ្ញា និង ៥៥០ ទំព័រសម្រាប់ភាគីនីមួយៗ ហើយបានកំណត់កាលបរិច្ឆេទត្រឹមថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧។ អង្គជំនុំ-ជម្រះបានពន្យារពេលកំណត់សម្រាប់សហមេធាវីនាំមុខរហូតដល់ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៧ សម្រាប់ដាក់សំណើសុំទាមទារសំណងចុងក្រោយ (ឯកសារ E449/1 កថាខណ្ឌ ៨-១០)។ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលគ្រោងធ្វើឡើងចាប់ពីថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៧ រយៈពេល ១០ ថ្ងៃ ដោយផ្តល់ឱ្យរយៈពេលមួយថ្ងៃសម្រាប់សហមេធាវីនាំមុខ បីថ្ងៃសម្រាប់សហព្រះរាជអាជ្ញា ពីរថ្ងៃសម្រាប់ជនជាប់ចោទម្នាក់ៗ មួយថ្ងៃសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានតប និងបួនម៉ោងសម្រាប់ជនជាប់ចោទធ្វើសេចក្តីថ្លែងចុងក្រោយ (ឯកសារ E449/1 កថាខណ្ឌ ១១)។

១១. តាំងពីពេលនោះមក អង្គជំនុំជម្រះបានទទួលស្គាល់នូវការលំបាកដោយសារកំណែប្រតិចារឹកសវនាការជាច្រើន ដែលកំពុងធ្វើឡើងនៅក្នុងពេលត្រៀមរៀបចំសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគី (ឯកសារ E449/3/6 កថាខណ្ឌ ៤)។ បច្ចុប្បន្ន ដំណើរការពិនិត្យមើលប្រតិចារឹកឡើងវិញត្រូវបានព្យាករណ៍ទុកថានឹងបញ្ចប់ត្រឹមថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៧ ចំពោះប្រតិចារឹកជាភាសាអង់គ្លេស និងថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៧ ចំពោះប្រតិចារឹកជាភាសាខ្មែរ និងបារាំង។ យោងតាមព័ត៌មានចុងក្រោយបំផុតនាពេលថ្មីៗ ដែលផ្តល់ជូនពីខាងអង្គភាពប្រតិចារឹក (ឯកសារ E449/3/6/2) ប្រសិនបើគិតត្រឹមថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៧ នៅសល់ប្រតិចារឹកសរុបចំនួន ២៤០ ទៀត (៦៨ ជាភាសាអង់គ្លេស, ៩០ ជាភាសាខ្មែរ និង ៨២ ជាភាសាបារាំង) ដែលពុំទាន់ពិនិត្យបញ្ចប់ក្រោយពីដំណើរការពិនិត្យមើលប្រតិចារឹកឡើងវិញនោះទេ។ អង្គជំនុំជម្រះយល់ឃើញថា ដំណើរការពិនិត្យមើលប្រតិចារឹកឡើងវិញមានគោលបំណងផ្តល់កំណត់ត្រាភស្តុតាងមួយដែលអាចទុកចិត្តបាន ដែលបានធ្វើឡើងនៅក្នុងតុលាការក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២។ ហេតុដូច្នេះមានតែប្រតិចារឹកដែលត្រូវបានពិនិត្យចប់សព្វគ្រប់ប៉ុណ្ណោះ ដែលអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការពិភាក្សាដេញដោលពីភស្តុតាង។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះក៏ត្រូវធានាថា

កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២ អាចបញ្ចប់ឱ្យបានឆាប់រហ័ស និងទាន់ពេលវេលាកំណត់។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ដំណើរការព្រាងសាលក្រមអាចដំណើរការទៅមុខបានលឿនដរាបណា អង្គជំនុំជម្រះមានឱកាសវាយតម្លៃលើទឡ្ហីករណ៍ដែលបានលើកឡើងដោយភាគីនៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។ អង្គជំនុំជម្រះយល់ឃើញបន្ថែមទៀតថា ទោះបីជាដំណើរការពិនិត្យមើលប្រតិចារឹកឡើងវិញអាចប៉ះពាល់ដល់ខ្លឹមសារសារធាតុនៃប្រតិចារឹកក៏ដោយ ក៏ផលប៉ះពាល់នេះនឹងទំនងជាមានតិចតួច ហើយវាមិនរារាំងដល់ភាគី ក្នុងការដាក់សារណាប្រកបដោយអត្ថន័យនៅមុនពេលប្រតិចារឹកទាំងអស់ត្រូវបានពិនិត្យចប់សព្វគ្រប់នោះឡើយ។

១២. នៅពេលថ្លឹងថ្លែងពីការពិចារណាទាំងនេះ អង្គជំនុំជម្រះពិនិត្យឃើញថា មេធាវីការពារក្តី នួន ជា ស្នើសុំឱ្យទុកឱកាសឱ្យភាគីដាក់ "កំណែ" លើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ពួកគេដើម្បីបញ្ចូលចំណុចកែប្រែ ក្នុងគោលបំណងចង្អុលបញ្ជាក់ចំណុចយោង និងខ្លឹមសារនានាក្រោយពេលប្រតិចារឹកទាំងអស់ត្រូវបានពិនិត្យចប់សព្វគ្រប់។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីជាពាក្យ "កំណែ" ជាធម្មតាសំដៅលើការកែប្រែលើកំហុសអក្ខរាវិរុទ្ធ និងទម្រង់ក៏ដោយ ក៏មេធាវីការពារក្តី នួន ជា បានស្នើសុំអនុញ្ញាតដាក់កំណែលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលដោយផ្អែកលើ និងកម្រិតត្រឹមតែកំណែលើខ្លឹមសារដែលកើតចេញពីប្រតិចារឹកដែលត្រូវបានពិនិត្យកែតម្រូវ ហើយដែលមេធាវីការពារក្តីមិនទាន់ទទួលបាននៅពេលដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ យោងតាមកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះពិចារណាឃើញថា សំណើសុំដាក់ "កំណែសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល" គឺជាវិធីសាស្ត្រសមហេតុផលក្នុងការធានាបាននូវការជជែកដេញដោលចំពោះមុខលើភស្តុតាងដែលបានផ្តល់ជូននៅពេលជំនុំជម្រះ និងការចេញសាលក្រមបានទាន់ពេលវេលា។

១៣. អង្គជំនុំជម្រះទទួលបានសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលកំណត់ចំនួនពីរសប្តាហ៍ដើម្បីដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ហើយនឹងសំណើពីសហមេធាវីនាំមុខសុំពន្យារពេលយូរបន្ថែមទៀត ពោលគឺ រយៈពេលជិតប្រាំមួយសប្តាហ៍។ សំណើសុំរបស់ ក.ស.ព ផ្តោតលើប្រតិចារឹកអាទិភាពទាំងនេះដែលត្រូវបានកំណត់ដោយមេធាវីការពារក្តី ខៀវ សំផន និងអង្គជំនុំជម្រះសាលាដំបូង ក្នុងនោះ មានប្រតិចារឹកចំនួន ៩៨ ផ្សេងទៀត

ដែលនៅសេសសល់នៅពេលសហព្រះរាជអាជ្ញាដាក់សំណើសុំ (ឯកសារ E449/3/6/1 កថាខណ្ឌ ៣(គ)) ហើយនឹងប្រតិចារឹកចំនួនតែប្រាំពីរប៉ុណ្ណោះ (ជាភាសាខ្មែរទាំងអស់) ដែលនៅសេសសល់ត្រឹមថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៧ (ឯកសារ E449/3/6/2)។ អង្គភាពប្រតិចារឹកធ្លាប់បានប៉ាន់ស្មានថា កំណែប្រតិចារឹកអាទិភាពទាំងនេះនឹងត្រូវបញ្ចប់ត្រឹមថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧ (ឯកសារ E449/3/5 កថាខណ្ឌ ២(ខ))។ សំណើសុំរបស់សហមេធាវីនាំមុខលើកទីពីរផ្តោតលើប្រតិចារឹកនៃដើមបណ្តឹងរដ្ឋប្បវេណី ហើយនឹងអនុញ្ញាតឱ្យពួកគេចៀសផុតពីភាពចាំបាច់ក្នុងការដាក់កំណែខ្លឹមសារ លើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនាពេលក្រោយ។

១៤. អង្គជំនុំជម្រះកត់សម្គាល់ថា សំណើសុំទាំងនេះមានលក្ខណៈរួមគ្នា គឺសុំពន្យារពេលកំណត់លើការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ដែលដំណើរការកែប្រែប្រតិចារឹកនៅមិនទាន់អាចដោះស្រាយបានចប់សព្វគ្រប់ ដូច្នេះ វានាំឱ្យខាតបង់ពេលវេលារបស់អង្គជំនុំជម្រះក្នុងការចាប់ផ្តើមដំណើរការព្រាងសាលក្រម។ អង្គជំនុំជម្រះនឹងនៅតែអនុញ្ញាតឱ្យដាក់កំណែសារណាដដែលនៅក្នុងករណីទាំងពីរនេះ។

១៥. ដោយសារចំនួនប្រតិចារឹកចំពោះមុខ និងដូចបានបញ្ជាក់តាមរយៈអ៊ីមែលជូនភាគីកាលពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០១៧ អង្គជំនុំជម្រះយល់ឃើញថា ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧ គឺជាកាលបរិច្ឆេទសមស្របសម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលទាំងអស់។ ការពន្យារពេលលើកាលបរិច្ឆេទដោយសារបញ្ហានេះនឹងមានតិចតួច ហើយវារក្សានូវសិទ្ធិរបស់ភាគីក្នុងការទទួលបានការជជែកដេញដោលពេញលេញលើភស្តុតាងផងដែរ។

១៦. ផ្អែកតាមការពិភាក្សាខាងលើ ភាគីទាំងអស់ត្រូវបានអនុញ្ញាតឱ្យដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលដែលមានការកែប្រែ ហើយកាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់សារណាកែតម្រូវនេះ នឹងត្រូវកំណត់បន្ទាប់ពីបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដែលនៅពេលនោះ អង្គជំនុំជម្រះនឹងទទួលបានព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពទាក់ទងនឹងការបញ្ចប់ដំណើរការពិនិត្យមើលប្រតិចារឹកឡើងវិញ ដូចដែលបានរំពឹងទុក។ សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលដែលមានការកែប្រែ ត្រូវកម្រិតត្រឹមការកែប្រែទៅលើបញ្ហាសំខាន់ៗ និងការកែតម្រូវទំព័រយោងដែលបានមកពីការកែតម្រូវប្រតិចារឹកចុងក្រោយ

ដែលជាផ្នែកមួយនៃដំណើរការពិនិត្យមើលប្រតិចារឹកឡើងវិញ និងដែលបានដាក់ជូន បន្ទាប់ពីការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលដើម។ សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលដែលមានការកែប្រែនេះ ត្រូវដាក់បញ្ចូលនូវរាល់ការកែប្រែទាំងអស់ដែលមាននៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលដើម ដោយមានរំលេចជាពណ៌ (highlighting) ត្រង់ចំណុចកែប្រែ ដែលការធ្វើរបៀបនេះបញ្ជាក់ថាវាជាសារណាមួយពេញលេញ និងជាចុងក្រោយ។ អង្គជំនុំជម្រះនឹងមិនទទួលយកឯកសារដាច់ដោយឡែក ដែលគ្រាន់តែរៀបរាប់ពីការកែតម្រូវនានាទៅលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលដើមនោះទេ។ ក្នុងករណីចាំបាច់ អង្គជំនុំជម្រះនឹងពិចារណាទៅលើសំណើសុំដាក់ចម្លើយតបមានកម្រិត ទៅនឹងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនានាដែលបានការកែប្រែនេះ។

១៧. អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចត្រង់ផ្នែកខ្លះនៃសំណើរបស់ ក.ស.ព និងកំណត់កាលបរិច្ឆេទចុងក្រោយត្រឹម<u>ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧</u> សម្រាប់ដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។ យោងតាមសេចក្តីសម្រេចនេះ កាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់បញ្ជីឯកសារច្បាប់ត្រូវបានពន្យាររហូតដល់ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧។ ក្នុងករណីដែលសហមេធាវីនាំមុខ សម្រេចដាក់បណ្តឹងទាមទារសំណងជាចុងក្រោយដាច់ដោយឡែកពីគ្នានោះ កាលបរិច្ឆេទចុងក្រោយត្រូវបានពន្យាររហូតដល់<u>ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧</u>។

១៨. ចំពោះសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលវិញ អង្គជំនុំជម្រះបានពិចារណាទៅលើសារណារបស់ភាគីទាំងអស់ និងបានកែប្រែកាលបរិច្ឆេទទៅតាមនោះ ដូចមានបញ្ជាក់ជូនខាងក្រោម។ អង្គជំនុំជម្រះយល់ឃើញថា ការកំណត់ពេលវេលានេះ គឺជាការគោរពដល់សិទ្ធិរបស់ភាគីដើម្បីត្រៀមរៀបចំ និងធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន ហើយក៏អាចឱ្យអង្គជំនុំជម្រះបញ្ចប់កិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២/០២ ក្រោយរយៈពេលតែពីរថ្ងៃប៉ុណ្ណោះពីកាលបរិច្ឆេទដែលបានគ្រោងទុកមុន (*សូមមើល* ឯកសារ E449/1, កថាខណ្ឌ ១១)។ ជាពិសេស អង្គជំនុំជម្រះបានកត់សម្គាល់ទៅលើសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា ដែលសុំឱ្យទុកពេលវេលាយ៉ាងហោចណាស់ក៏ពីរថ្ងៃដែរ សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ ក្នុងន័យនេះ រយៈពេលបីថ្ងៃដែលបានផ្តល់ឱ្យក្រុមមេធាវីការពារក្តីទាំងអស់ អាចនឹងត្រូវបានចែករំលែកគ្នា អាស្រ័យទៅតាមការព្រមព្រៀងគ្នាក្នុងចំណោម

មេធាវីការពារក្តីទាំងពីរក្រុម។ ក្នុងករណីដែលក្រុមមេធាវីការពារក្តី នួន ជា មិនទទួលបាន ពេលវេលាចំនួនពីរថ្ងៃដូចបានស្នើសុំទេនោះ ពេលវេលាបន្ថែមអាចនឹងត្រូវបានផ្តល់ជូន ប្រសិនបើវាមិនឈានដល់ការជំទាស់តវ៉ាច្រំដែល ឬមានចេតនាពន្យារកិច្ចដំណើរការនីតិវិធីដោយមិនមានយុត្តិកម្មទេនោះ។

១៩. អាស្រ័យហេតុនេះ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនឹងត្រូវចាប់ផ្តើម<u>ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៧</u> ដូចខាងក្រោមនេះ៖

| | |
|---|---|
| សហមេធាវីនាំមុខ | ១៣ មិថុនា ២០១៧ (១ ថ្ងៃ) |
| សហព្រះរាជអាជ្ញា | ១៤-១៥ មិថុនា ២០១៧ (២ ថ្ងៃ) |
| នួន ជា/ខៀវ សំផន | ១៦, ១៩-២០ មិថុនា ២០១៧ (៣ ថ្ងៃ) |
| សេចក្តីសន្និដ្ឋានតបរបស់ (សហមេធាវីនាំមុខ/ក.ស.ព) | ២១ មិថុនា (១ ថ្ងៃ) |
| សេចក្តីថ្លែងចុងក្រោយរបស់ (នួន ជា/ខៀវ សំផន) | ២២ មិថុនា (៤ ម៉ោង) |
| កាលបរិច្ឆេទបម្រុង | ២៣ មិថុនា |

២០. យោងតាមសេចក្តីសម្រេចខាងលើ ទាក់ទងនឹងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលដែលមានការកែប្រែ និងសំណើពាក់ព័ន្ធរបស់ នួន ជា សុំធនធានបន្ថែមនោះ អង្គជំនុំជម្រះនឹងបញ្ជូនសំណើសុំ និងសេចក្តីសម្រេចនេះទៅកាន់ការិយាល័យរដ្ឋបាល ដើម្បីពិចារណាតាមការសមស្រប។

២១. ជាចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ទាំងសហមេធាវីនាំមុខ និងក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យមានការបញ្ជាក់បំភ្លឺទាក់ទងនឹងស្ថានភាពនៃប្រតិចារឹកនីមួយៗ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីនាំមុខហាក់ដូចជាទទួលបានព័ត៌មានដែលបានស្នើសុំនេះផ្ទាល់ពីអង្គភាពប្រតិចារឹករួចហើយ (ឯកសារ E457/4) ហេតុដូច្នេះ សំណើសុំនេះចាត់ទុកជាអសារបង់។ អង្គជំនុំជម្រះកត់សម្គាល់ឃើញបន្ថែមទៀតថា ការធ្វើបច្ចុប្បន្នភាពទៅលើដំណើរការពិនិត្យមើលប្រតិចារឹកឡើងវិញ កាលពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៧ (ឯក

សារ E449/3/6/2) អង្គភាពប្រតិចារិកបានផ្តល់ការបញ្ជាក់បំភ្លឺ ដើម្បីជាការឆ្លើយតបទៅនឹងក្រុមមេធាវីការពារក្តី នួន ជា រួចហើយ។ ក្នុងករណីមានសំណួរសេសសល់ផ្សេងទៀតពីភាគីណាមួយ អង្គជំនុំជម្រះបង្គាប់ឲ្យសាកសួរទៅកាន់អង្គភាពប្រតិចារិកដោយផ្ទាល់តែម្តង។

២២. សេចក្តីសម្រេចនេះ ចាត់ទុកជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងឯកសារ E457, E457/1, E457/2, E457/3, E457/4 និង E457/5។